**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
លេខៈ០១/២៣ ប្រ.អអរ

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ជោគជ័យ នៃបេសកកម្មរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៣**
**និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅរដ្ឋធានីហ្សាការតា សាធារណរដ្ឋឥណ្ឌូនេស៊ី**
**ពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងគណៈប្រតិភូជាន់ខ្ពស់ បានអញ្ជើញធ្វើមាតុភូមិនិវត្តន៍មកដល់រាជធានីភ្នំពេញវិញហើយ នាវេលាយប់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣ បន្ទាប់ពីបានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅរដ្ឋធានីហ្សាការតា នៃសាធារណរដ្ឋឥណ្ឌូនេស៊ី ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣ តបតាមការអញ្ជើញរបស់ **ឯកឧត្តម ចូកូ វីដូដូ** ប្រធានាធិបតី នៃសាធារណរដ្ឋឥណ្ឌូនេស៊ី និងជាប្រធានអាស៊ាន។

ក្នុងរយៈពេល៤ថ្ងៃ នៃបេសកកម្មនេះ ប្រមុខដឹកនាំ នៃរាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ចំនួន១៣កិច្ចប្រជុំ អញ្ជើញថ្លែងសុន្ទរកថាចំនួន១២លើក និងអញ្ជើញជួបពិភាក្សាទ្វេភាគី ត្រីភាគី និងជំនួបក្រៅផ្លូវការជាមួយប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងថ្នាក់ដឹកនាំកំពូល នៃស្ថាប័នតំបន់ និងអន្តរជាតិជាច្រើនទៀត។

ក្នុងក្របខណ្ឌ នៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលធុរកិច្ច និងវិនិយោគអាស៊ាន កិច្ចប្រជុំកំពូលអាស៊ានលើកទី៤៣ ដែលប្រារព្ធពិធីបើកក្រោមអធិបតីភាព **ឯកឧត្តម ចូកូ វីដូដូ** ប្រធានាធិបតី នៃសាធារណរដ្ឋឥណ្ឌូនេស៊ី វេទិកាអាស៊ាន-ឥណ្ឌូប៉ាស៊ីហ្វិក ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាសម្រាប់ដៃគូក្នុងការអភិវឌ្ឍកសិកម្ម និងសហគ្រាសមីក្រូ-ធុនតូច និងមធ្យមកម្ពុជា-ហ្វីលីពីន កិច្ចប្រជុំកំពូលអាស៊ាន-ចិនលើកទី២៦ កិច្ចប្រជុំកំពូលអាស៊ាន-កូរ៉េលើកទី២៤ កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុនលើកទី២៦ កិច្ចប្រជុំកំពូលអាស៊ានបូក៣(ចិន ជប៉ុន កូរ៉េ)លើកទី២៦ កិច្ចប្រជុំកំពូលអាស៊ាន-សហរដ្ឋអាមេរិកលើកទី១១ កិច្ចប្រជុំកំពូលអាស៊ាន-កាណាដា កិច្ចប្រជុំ

កំពូលអាស៊ាន-ឥណ្ឌាលើកទី២០ កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី១៨ កិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលី លើកទី៣ និងកិច្ចប្រជុំកំពូលអាស៊ាន-អង្គការសហប្រជាជាតិលើកទី១៣។

ក្នុងក្របខណ្ឌទ្វេភាគី និងត្រីភាគី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានអញ្ជើញជួបពិភាក្សាទ្វេភាគីជាមួយ អគ្គលេខាធិការអាស៊ាន ប្រធានាធិបតីឥណ្ឌូនេស៊ី នាយករដ្ឋមន្ត្រីវៀតណាម នាយករដ្ឋមន្ត្រីម៉ាឡេស៊ី នាយករដ្ឋមន្ត្រីសិង្ហបុរី ស្ថាបនិកនិងជាប្រធានប្រតិបត្តិ នៃវេទិកាសេដ្ឋកិច្ចពិភពលោក ព្រះចៅស៊ុលតង់ ប្រទេសព្រុយណេដារូស្សាឡាម នាយករដ្ឋមន្ត្រីចិន ប្រធានាធិបតីហ្វីលីពីន ប្រធានាធិបតីកូរ៉េខាងត្បូង នាយករដ្ឋមន្ត្រីកោះយុក នាយករដ្ឋមន្ត្រីជប៉ុន និងបានជំនួបពិភាក្សាត្រីភាគី ជាមួយនាយករដ្ឋមន្ត្រីវៀតណាម និងនាយករដ្ឋមន្ត្រីឡាវ។ **សម្តេចមហាធិបតី** ក៏បានឆ្លៀតជួបសំណេះសំណាលក្រៅផ្លូវការជាមួយអនុប្រធានាធិបតីអាមេរិក នាយករដ្ឋមន្ត្រីអូស្ត្រាលី នាយករដ្ឋមន្ត្រីឥណ្ឌា បណ្តាប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ព្រមទាំងថ្នាក់ដឹកនាំស្ថាប័នតំបន់ និងអន្តរជាតិផ្សេងទៀត។ ក្នុងដំណើរបំពេញបេសកកម្មក្រៅប្រទេសជាលើកដំបូងនេះ **សម្តេចមហាបវរធិបតី** និងគណៈប្រតិភូជាន់ខ្ពស់កម្ពុជា សម្រេចបានជោគជ័យយ៉ាងធំធេងសម្រាប់ប្រទេសជាតិ និងប្រជាពលរដ្ឋ។

*នៅលើវិស័យនយោបាយការទូត* ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ថ្នាក់ដឹកនាំកំពូលៗនៃស្ថាប័នតំបន់ និងអន្តរជាតិ បានចូលរួមអបអរសាទរប្រកបដោយមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅ និងគាំទ្រ **សម្តេចមហាបវរធិបតី** ដែលត្រូវបានជ្រើសតាំងជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា និងបានជម្រាបជូននូវសេចក្តីផ្តាំផ្ញើប្រកបដោយការនឹករលឹកបំផុត ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាអតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។** **សម្តេចធិបតី** ក៏បានថ្លែងអំណរគុណចំពោះមេដឹកនាំបរទេសទាំងនោះដែលបានអបអរសាទរចំពោះ **សម្តេច** និងបានផ្តាំផ្ញើនូវមនោសញ្ចេតនានឹករលឹកជូន **សម្តេចតេជោ**។

ក្នុងកិច្ចសន្ទនាទ្វេភាគី ត្រីភាគី និងក្រៅផ្លូវការនោះដែរ **សម្តេចមហាបវរធិបតី** និងប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ព្រមទាំងថ្នាក់ដឹកនាំកំពូល នៃស្ថាប័នតំបន់ និងអន្តរជាតិ ក៏បានពិភាក្សា អំពីការបន្តពង្រឹង និងពង្រីកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការគ្រប់វិស័យ ព្រមទាំងបានផ្លាស់ប្តូរយោបល់អំពីបញ្ហាតំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍ និងក្តីបារម្ភរួម។ ក្នុងឱកាសនោះ **សម្តេចមហាបវរធិបតី** ក៏បានទទួលការអញ្ជើញទៅបំពេញទស្សនកិច្ច និងអញ្ជើញចូលរួមវេទិកាសេដ្ឋកិច្ចពិភពលោកផងដែរ។ **សម្តេចប្រមុខរាជរដ្ឋាភិបាលកម្ពុជា** ក៏បានអញ្ជើញមេដឹកនាំជាច្រើន មកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ក្នុងពេលវេលាសមស្របណាមួយខាងមុខ។

នៅក្នុងសុន្ទរកថាទៅកាន់វេទិកា និងកិច្ចប្រជុំនានា **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារសំខាន់នៃ **សន្តិភាព** នៅក្នុងតំបន់ និងពិភពលោក ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់មនុស្សជាតិគ្រប់ប្រទេស និងគ្រប់តំបន់។ **សម្តេចធិបតី** បានថ្លែងជាអាទិ៍ថា សង្គ្រាមមិនអាចបញ្ចប់ដោយសង្គ្រាមបានឡើយ ហើយក៏គ្មានការអភិវឌ្ឍណាអាចកើតឡើងដោយគ្មានសុខសន្តិភាពពេញលេញនោះដែរ។

គួរកត់សម្គាល់ថា **សម្តេចធិបតី ហ៊ុន ម៉ាណែត** បានក្លាយជាតួអង្គមេដឹកនាំដ៏លេចធ្លោនៅគ្រប់វេទិកា និងគ្រប់កិច្ចប្រជុំកំពូលអាស៊ាន ពីព្រោះ **សម្តេច** ជានាយករដ្ឋមន្ត្រីវ័យក្មេងជាងគេ ប៉ុន្តែបានបង្ហាញនូវទេពកោសល្យ

ការទូតដ៏ប៉ិនប្រសប់ និងលេចធ្លោ ជាពិសេសក្នុងកិច្ចសន្ទនាជាអន្តរជាតិកម្រិតខ្ពស់ជាមួយមេដឹកនាំក្នុងតំបន់ និងមហាអំណាចលើពិភពលោក ដូចដែលកម្ពុជាធ្លាប់បានធ្វើ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី។

***លើវិស័យសេដ្ឋកិច្ចវិញ*** **សម្តេចធិបតី** បានភ្ជាប់ជានិច្ច នូវកិច្ចពិភាក្សាអំពីវិស័យ ដែលមានសក្តានុពលសម្រាប់កិច្ចសហប្រតិបត្តិការទាំងទ្វេភាគី និងពហុភាគី នៅគ្រប់ជំនួប។ ថ្នាក់ដឹកនាំទាំងអស់ក៏បានឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា លើវិស័យជាច្រើន មានជាអាទិ៍ វិស័យពាណិជ្ជកម្ម វិនិយោគកសិកម្ម អប់រំ ទេសចរណ៍ វប្បធម៌ ការតភ្ជាប់ខ្សែច្រវាក់ផលិតកម្ម និងការតភ្ជាប់រវាងប្រជាជន និងប្រជាជន។ ជាក់ស្តែង **សម្តេចធិបតី** បានអញ្ជើញជាសាក្សី ជាមួយ **ឯកឧត្តមប្រធានាធិបតី** ហ្វីលីពីន ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាសម្រាប់ភាពជាដៃគូ ក្នុងការអភិវឌ្ឍកសិកម្ម និងសហគ្រាសមីក្រូ-ធុនតូចនិងមធ្យម កម្ពុជា-ហ្វីលីពីន និងបានទទួលការឯកភាពគាំទ្រពីប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល នៃបណ្តាប្រទេសក្នុងតំបន់មួយចំនួន ក្នុងការបង្កើនការនាំចូលទំនិញមួយចំនួនពីកម្ពុជា ទៅកាន់ទីផ្សារប្រទេសទាំងនោះ ដូចជាប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និងម៉ាឡេស៊ី មទាំងផលិតផលអង្ករជាដើម។

ជារួមក្នុងអំឡុងពេលបំពេញបេសកម្មចូលរួមកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅទីក្រុងហ្សាការតា សាធារណរដ្ឋឥណ្ឌូនេស៊ី ពីថ្ងៃទី៤ រហូតដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣ **សម្តេចមហាបវរធិបតី** បានអញ្ជើញចូលរួមកិច្ចប្រជុំ កិច្ចពិភាក្សាទ្វេភាគី ត្រីភាគី និងកិច្ចសន្ទនាក្រៅផ្លូវការ **ចំនួន៣២លើក** ជាមួយប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ថ្នាក់ដឹកនាំកំពូលស្ថាប័នតំបន់ និងអន្តរជាតិ មិនតិចជាង**២០រូប**ឡើយ។ ទន្ទឹមគ្នានោះដែរ មានធុរជនអញ្ជើញមកពីប្រទេសក្នុងតំបន់អាស៊ាន និងអន្តរជាតិជាច្រើនរូប ក៏បានបង្ហាញបំណងចង់ជួបសម្តែងការគួរសម ជាមួយ **សម្តេចធិបតី** ដើម្បីបង្ហាញការគាំទ្រ និងបំណងចង់មកបណ្តាក់ទុកវិនិយោគនៅកម្ពុជាផងដែរ។

ក្នុងឱកាសរួមដំណើរជាមួយ **សម្តេចមហាបវរធិបតី** អញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៣ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនោះដែរ **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ក៏បានអញ្ជើញចូលរួមក្នុងកម្មវិធីសម្រាប់ភរិយាថ្នាក់ដឹកនាំជាន់ខ្ពស់ នៃបណ្តាប្រទេសអាស៊ាន និងប្រទេសដៃគូអាស៊ាន ដោយមានវត្តមាន **លោកជំទាវ** ជាភរិយាថ្នាក់ដឹកនាំជាន់ខ្ពស់សរុបចំនួន១១រូបអញ្ជើញចូលរួមផងដែរ។ កម្មវិធីនេះមានការសម្តែងនិងបង្ហាញអំពីសិល្បៈវប្បធម៌ចម្រុះ និងមានការដាក់តាំងបង្ហាញនូវផលិតផលក្នុងស្រុកនានា នៃប្រទេសឥណ្ឌូនេស៊ី ដែលជាផ្នែកមួយ នៃការផ្លាស់ប្តូរផ្នែកវប្បធម៌ ទេសចរណ៍ និងពាណិជ្ជកម្ម។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣